ក្រសួងអប់រំ យុវជន និងកីឡា

សៀវភៅពន្លឿនការសិក្សា

សិក្សាសង្គម

ថ្នាក់ឆ្នាំទី ១



សម្រាប់គ្រូបង្រៀន

ព.ស. ២៥៥៨ គ.ស. ២០១៤



ក្រសួងអប់រំ យុវជន និងកីឡា

សៀវភៅពន្យឿនការសិក្សា

សិក្សាសង្គម

ថ្នាក់ឆ្នាំទី ១

ឯកសារសម្រាប់គ្រូ

បោះពុម្ពលើកទី ២
ឆ្នាំ ២០១៥

គណៈកម្មការត្រួតត្រង

ឯកឧត្តម ណាត ប៊ុនរឿន	លោក អ៊ុក សុវណ្ណ
ឯកឧត្តម អ៊ឹម កុច	លោក ចាន់ សុភា
ឯកឧត្តម សំ សេរីរតន៍	លោក ជា វណ្ណេត

គណៈកម្មការនិពន្ធ

លោកស្រី ទូច សុភាព	លោកស្រី ឡាច សុម៉ាលី
លោកស្រី សាន ណាវ៉ា	លោកស្រី អៃ ចាន់ម៉ាលី
លោកស្រី ជឹម យ៉ាធីតា	លោកស្រី ពៅ រដ្ឋា

អ្នករៀបរៀងនិងរចនាចំណារ

លោកស្រី ខ្វង់ គឹមទូច	លោក អាន រ៉ូប្រាវ

គណៈកម្មការត្រួតពិនិត្យ

លោក ជា វណ្ណេត	លោកស្រី ខ្វង់ គឹមទូច
លោក អាន រ៉ូប្រាវ	លោកស្រី មិន វិចិត្រា
លោកស្រី ហ៊ុន សុជាតិ	

បញ្ជីអត្ថបទ

អារម្ភកថា ១
ផ្នែកទី១៖ បំណែងចែកកម្មវិធីសិក្សា ២
ផ្នែកទី២៖ លំនាំនៃការបង្រៀន ៥
ផ្នែកទី៣៖ សលាកបត្រជំពូកនិងមេរៀន ៨
ជំពូកទី១ : ទម្លាប់ល្អរបស់គ្រួសារខ្ញុំ ៩
ជំពូកទី២ : កន្លែងដែលខ្ញុំរស់នៅ ១១
ជំពូកទី៣ : ការបង្ការគ្រោះថ្នាក់នៅតាមផ្ទះ ១៣
ជំពូកទី៤ : កិច្ចការប្រចាំថ្ងៃរបស់ខ្ញុំ ១៤
ជំពូកទី៥ : ទម្លាប់ល្អនៅសាលារៀន ១៧
ជំពូកទី៦ : ចម្រៀងនិងការកម្សាន្ត ១៩
ជំពូកទី៧ : សុវត្ថិភាពក្នុងការធ្វើដំណើរ ២១
ជំពូកទី៨ : សុវត្ថិភាពក្នុងការលេងទឹក ២៤
ជំពូកទី៩ : ចៀសវាងពីការគំរាមកំហែង ២៦
ជំពូកទី១០ : ទីតាំងសាលារៀននិងភូមិ ២៨
ជំពូកទី១១ : ប្រវត្តិសាលារៀននិងភូមិខ្ញុំ ៣០
ជំពូកទី១២ : ខ្ញុំហាត់រាំ ៣៣
ជំពូកទី១៣ : ព្រះមហាក្សត្រនិងអ្នកដឹកនាំប្រទេស ៣៨

អារម្ភកថា

ឯកសារជំនួយគ្រូមុខវិជ្ជា សិក្សាសង្គមថ្នាក់ឆ្នាំទី១ នេះ ត្រូវបានរៀបចំឡើងក្រោមកិច្ចសហប្រតិបត្តិការ រវាងក្រសួងអប់រំ យុវជន និងកីឡា ជាមួយនឹងអង្គការ ដើម្បីកាពញញឹមនៃកុមារ នៅក្នុងគម្រោងចងក្រងសៀវភៅពន្លឿនការសិក្សាសម្រាប់សាលាបឋមសិក្សា។ ឯកសារនេះ ត្រូវបានចងក្រងឡើងដោយគណៈកម្មការនិពន្ធក្នុងគម្រោងនេះ និងដោយមានការចូលរួម ពីលោកគ្រូអ្នកគ្រូដែលបង្រៀនថ្នាក់ពន្លឿនការសិក្សានៅអង្គការ ដើម្បីកាពញញឹមនៃកុមារ។

ឯកសារនេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណង សម្រួលដល់ការបង្រៀនមុខវិជ្ជាសិក្សាសង្គម ថ្នាក់ឆ្នាំទី១ របស់លោកគ្រូអ្នកគ្រូ។ ខ្លឹមសារសំខាន់នៃឯកសារនេះ មានការបង្ហាញពីកម្មវិធីពន្លឿនការសិក្សា នៅសាលាបឋមសិក្សា លំនាំនៃការបង្រៀនតាមសមត្ថភាពនីមួយៗ និងសលាកប័ត្រជំពូកនិងមេរៀន ពិសេស ផ្តោតទៅលើចម្លើយរបស់សំណួរ និងកំណែលំហាត់ដែលផ្តល់នូវភាពងាយស្រួល សម្រាប់លោកគ្រូអ្នកគ្រូក្នុងការប្រើប្រាស់សៀវភៅពន្លឿនការសិក្សា។

ក្នុងការបង្រៀន គណៈកម្មការយើងមិនទាមទារឱ្យលោកគ្រូអ្នកគ្រូអនុវត្តឯកសារនេះ ទាំងស្រុងនោះទេ។ ប៉ុន្តែកត្តាសំខាន់ គឺជំរុញឱ្យការសិក្សារបស់សិស្សទទួលបានលទ្ធផលល្អប្រពៃ ដោយពឹងផ្អែកលើចំណេះដឹង បទពិសោធ ក្នុងការរៀបចំវិធីបង្រៀន បំណិនប្រសប់ក្នុងការប្រើប្រាស់វាក្យសព្ទ និងសម្ភារឧបទេសក្នុងការបង្រៀនរបស់លោកគ្រូអ្នកគ្រូ។

ក្រោយពីបញ្ចប់មេរៀននីមួយៗ លោកគ្រូអ្នកគ្រូ ធ្វើរង្វាយតម្លៃលើកម្រិតយល់ដឹងរបស់សិស្ស ដោយធ្វើសំណួរសរសេរ ឬសំណួរផ្ទាល់មាត់ ឬលំហាត់អនុវត្ត ព្រោះវាអាចបង្ហាញឱ្យគ្រូដឹងពីលទ្ធផលបង្រៀន ដើម្បីឱ្យលោកគ្រូអ្នកគ្រូជ្រើសរើសនិងកែសម្រួលវិធីសាស្ត្របង្រៀនឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត។

គណៈកម្មការនិពន្ធសង្ឃឹមថា ឯកសារជំនួយគ្រូសិក្សាសង្គម ថ្នាក់ឆ្នាំទី១ នេះ នឹងបានជាប្រយោជន៍ច្រើន ដល់ការបង្រៀនរបស់គ្រូ ដើម្បីរួមចំណែកក្នុងការលើកកម្ពស់គុណភាពរៀននិងបង្រៀនប្រកបដោយប្រសិទ្ធភាព។

គណៈកម្មការនិពន្ធ

ផ្នែកទី១
បំណែងចែកកម្មវិធីសិក្សា

កម្មវិធីសិក្សាថ្នាក់ពន្លឿនការសិក្សា មុខវិជ្ជាសិក្សាសង្គម ថ្នាក់ឆ្នាំទី១ នេះ គឺជាការសំយោគបញ្ចូលគ្នា រវាងកម្មវិធីសិក្សាមុខវិជ្ជា សិក្សាសង្គម ថ្នាក់ទី១ និងថ្នាក់ទី២ នៃកម្មវិធីសិក្សាគោលរបស់ក្រសួងអប់រំ យុវជន និងកីឡា។ មុខវិជ្ជាសិក្សាសង្គម ថ្នាក់ឆ្នាំទី១ នេះ មានចំនួន ២ម៉ោងសិក្សា ក្នុង ១សប្តាហ៍ ដែល ១ម៉ោងសិក្សាមានរយៈពេល ៤០នាទី។

ជំពូក	មេរៀន	ចំណងជើងមេរៀន	រយៈពេល
ទី១៖ ទម្លាប់ល្អរបស់គ្រួសារខ្ញុំ	១	ការណែនាំពីញាតិសន្តាន	២ម៉
	២	របៀបសំពះ	២ម៉
	៣	ទង្វើគួរធ្វើនិងទង្វើគួរចៀសវាង	២ម៉
ទី២៖ កន្លែងដែលខ្ញុំរស់នៅ	១	វត្ថុដែលមាននៅក្នុងផ្ទះខ្ញុំ	១ម៉
	២	វត្ថុដែលមាននៅជុំវិញផ្ទះខ្ញុំ	១ម៉
ទី៣៖ ការបង្ការគ្រោះថ្នាក់នៅតាមផ្ទះ	១	គ្រោះថ្នាក់ផ្សេងៗនៅតាមផ្ទះ	១ម៉
	២	ការបង្ការគ្រោះថ្នាក់	១ម៉
ទី៤៖ កិច្ចការប្រចាំថ្ងៃរបស់ខ្ញុំ	១	មុនពេលទៅសាលារៀន	២ម៉
	២	កិច្ចការខ្ញុំនៅសាលារៀន	២ម៉
	៣	កិច្ចការខ្ញុំនៅផ្ទះ	១ម៉
	៤	កូនល្អ សិស្សល្អ មិត្តល្អ	២ម៉
	៥	ខ្ញុំចូលចិត្តនិងមិនចូលចិត្ត	២ម៉
ទី៥៖ ទម្លាប់ល្អនៅសាលារៀន	១	ទម្លាប់ល្អនៅក្នុងនិងក្រៅថ្នាក់រៀន	១ម៉
	២	ទម្លាប់មិនល្អនៅក្នុងនិងក្រៅថ្នាក់រៀន	១ម៉
ទី៦៖ ចម្រៀងនិងការកម្សាន្ត	១	ភ្លេងជាតិ	១ម៉
	២	រង់ភ្លេង	១ម៉
	៣	របៀបបត់ ឬកាត់ក្រដាស	១ម៉
ទី៧៖ សុវត្ថិភាពក្នុងការធ្វើដំណើរ	១	ការបង្ការគ្រោះថ្នាក់នៅតាមដងផ្លូវ	២ម៉
	២	របៀបឆ្លងផ្លូវមានភ្លើងសញ្ញានិងគំនូសនៅលើផ្លូវថ្នល់	២ម៉
	៣	របៀបឆ្លងផ្លូវគ្មានភ្លើងសញ្ញា និងគ្មានគំនូសនៅលើផ្លូវថ្នល់	២ម៉
	៤	ភ្លើងសញ្ញាចរាចរណ៍ និងស្លាកសញ្ញាចរាចរណ៍	២ម៉
	៥	ការធ្វើដំណើរប្រកបដោយសុវត្ថិភាព	២ម៉
ទី៨៖ សុវត្ថិភាពក្នុងការលេងទឹក	១	ល្បែងផ្សេងៗរបស់កុមារ	២ម៉
	២	សុវត្ថិភាពក្នុងការលេងទឹក	២ម៉
ទី៩៖ ចៀសវាងពីការគំរាមកំហែង	១	ស្ថានភាពមានសុវត្ថិភាព	២ម៉
	២	ការចៀសវាងអំពើបង្ខិតបង្ខំ	២ម៉
	៣	អ្នកជួយការពារ	២ម៉
ទី១០៖	១	កន្លែងសំខាន់ៗនៅភូមិខ្ញុំ	២ម៉

ទីតាំងសាលារៀននិងភូមិខ្ញុំ	២	គូរផែនទីបង្ហាញទីតាំងសាលារៀន	២ម៉ោ
ទី១១៖ ប្រវត្តិសាលារៀននិងភូមិខ្ញុំ	១	ប្រវត្តិសាលារៀនខ្ញុំ	២ម៉ោ
	២	ប្រវត្តិភូមិខ្ញុំ	២ម៉ោ
	៣	ប្រវត្តិសង្កាត់ខ្ញុំ (សង្កាត់ព្រែកព្នៅ)	២ម៉ោ
	៤	ការថែរក្សាបរិស្ថានសាលារៀន	២ម៉ោ
ទី១២៖ ខ្ញុំហាត់រាំ	១	លំហាត់ពត់ដៃ ពត់ជើង	២ម៉ោ
	២	ចង្វាក់រាំវង់បែបទី១	២ម៉ោ
ទី១៣៖ ព្រះមហាក្សត្រ និងអ្នកដឹកនាំប្រទេស	១	ព្រះមហាក្សត្រ	១ម៉ោ
	២	សាសនា	១ម៉ោ
	៣	ជាតិ	១ម៉ោ
	៤	ថ្នាក់ដឹកនាំប្រទេស	១ម៉ោ

សរុបម៉ោងក្នុងមួយឆ្នាំសិក្សា

- សរុបម៉ោងទាំងអស់ ២ម៉ោ × ៣៨សប្តាហ៍ = ៧៦ ម៉ោងសិក្សា
- សរុបម៉ោងបង្រៀន ៦៤ ម៉ោងសិក្សា
- សរុបម៉ោងសល់ ១២ ម៉ោងសិក្សា

ផ្នែកទី២
លំនាំនៃការបង្រៀន

ផ្អែកតាមលទ្ធផលសិក្សារបស់សិស្សប៉ុន្មានឆ្នាំកន្លងមកនេះ យើងឃើញថា សិស្សបឋមសិក្សាមានមូលដ្ឋាននៃការស្រាវជ្រាវនៅមានកម្រិតទាបគួរឱ្យបារម្ភ។ ដើម្បីពង្រឹងគុណភាព នៃការស្រាវជ្រាវឱ្យកាន់តែប្រសើរ ដោយធ្វើការសម្របសម្រួលវិធីសាស្ត្រនិងកែលម្អឯកសារបង្រៀន សិក្សាសង្គម ថ្នាក់ទី១ និងថ្នាក់ទី២ របស់ក្រសួងអប់រំ យុវជន និងកីឡាមកជាសៀវភៅពន្លឿនការសិក្សា ថ្នាក់ឆ្នាំទី១ ដើម្បីឱ្យសិស្សក្នុងកម្រិតនេះ ចេះក្នុងទិសដៅឆ្លើយតបទៅនឹងកម្មវិធីពន្លឿនការសិក្សាសម្រាប់កម្រិតសិក្សា ថ្នាក់ឆ្នាំទី១ នេះ ។

ដើម្បីជាជំនួយដល់ការប្រើប្រាស់ សៀវភៅពន្លឿនការសិក្សានេះបានត្រឹមត្រូវ គណៈកម្មការបានរៀបចំសេចក្តីណែនាំដោយផ្តោតទៅលើ៖

១. ការប្រើប្រាស់សម្ភារៈ

ក្នុងការបង្រៀន លោកគ្រូ អ្នកគ្រូគប្បីប្រើប្រាស់សម្ភារឧបទេស ពីព្រោះវាជាមធ្យោបាយ ទាក់ទាញអារម្មណ៍សិស្សឱ្យចូលរួមក្នុងការបង្រៀន និងការរៀនយ៉ាងមានប្រសិទ្ធិភាព។ ជាពិសេស ធ្វើឱ្យសិស្សងាយចងចាំ សប្បាយរីករាយ តាមរយៈការលើកបង្ហាញ ពណ៌នា និងល្បែងសិក្សា។

២. លំនាំបង្រៀន

មេរៀន: ការណែនាំពីញាតិសន្តាន (២ម៉ោង)

សកម្មភាពទី១៖ បញ្ហា

- សួរទំនាក់ទំនង
- ដាក់បញ្ហាផ្ទាល់មាត់៖ *តើនរណាខ្លះជាញាតិសន្តាន?*
- សួរឡើងវិញពីបញ្ហា

- តើអម្ចាញ់មិញគ្រូសួរដូចម្តេច?
- តើប្អូនណាអាចនិយាយឡើងវិញបាន?

- សរសេរ ឬបិទបញ្ហាលើក្តារខៀន

បញ្ហា៖ *តើនរណាខ្លះជាញាតិសន្តាន?*

- សួរកវត្ថុបំណងនៃបញ្ហា តើបញ្ហានេះចង់ឱ្យប្អូនធ្វើអ្វី?
- កែតម្រូវចម្លើយរបស់សិស្ស

សកម្មភាពទី២៖ ការប៉ាន់ស្មាន

- ឱ្យសិស្សប៉ាន់ស្មានដាក់ក្នុងសៀវភៅស្រាវជ្រាវ ហើយផ្តល់ចម្លើយ
- សរសេរចម្លើយសិស្សដាក់លើក្តារខៀន៖ ជីដូន ជីតា ម្តាយឪពុក មា មីង ម្តាយធំ.....
- សួរបញ្ជាក់ពីចម្លើយរបស់សិស្ស៖ តើប្អូនដឹងថា ការប៉ាន់ស្មានរបស់ប្អូនពិតជាត្រឹមត្រូវឬទេ? បើមិនទាន់ដឹងច្បាស់ទេ តើប្អូនត្រូវធ្វើដូចម្តេចទៀត? (ស្រាវជ្រាវ)

សកម្មភាពទី៣៖ ការស្រាវជ្រាវ

- សួរសិស្សថា៖ តើប្អូនត្រូវមានអ្វី ដើម្បីស្រាវជ្រាវ? តើឯកសារទាំងនោះមានអ្វីខ្លះ?
- ឱ្យសិស្សបើកសៀវភៅសិក្សាសង្គម ថ្នាក់ឆ្នាំទី១ ទំព័រទី២ ដើម្បីស្រាវជ្រាវ។
- ណែនាំរបៀបស្រាវជ្រាវ៖ នៅពេលស្រាវជ្រាវ យើងត្រូវសង្កេត គូររូប កត់ត្រា និងទាញសេចក្តីសន្និដ្ឋានដាក់លើក្រដាសតាមក្រុមរៀងៗខ្លួនៗ ។

- កំណត់ពេល១៥នាទី
- ឱ្យសិស្សនិយាយការណែនាំការស្រាវជ្រាវឡើងវិញឱ្យបាន២ ឬ៣នាក់
- ចែកក្រុមពិភាក្សាដោយមានប្រធានក្រុម លេខាកត់ត្រា និងអ្នកបកស្រាយ
- ដើរពិនិត្យតាមក្រុម ដើម្បីណែនាំបន្ថែម ចំពោះការខ្វះចន្លោះរបស់សិស្ស

សកម្មភាពទី៤៖ របាយការណ៍ក្រុម

- ឱ្យតំណាងក្រុមនីមួយៗយកកិច្ចការរបស់ខ្លួនមកបិទលើក្តារខៀន
- ឱ្យតំណាងក្រុមឡើងបកស្រាយ
- ឱ្យសិស្សនៃក្រុមដទៃទៀតស្តាប់ការបកស្រាយ បើមានចំណុចណាដែលមិនយល់ ត្រូវសួរ ឯក្រុមបកស្រាយត្រូវឆ្លើយ។ បើសិនជាមិនអាចឆ្លើយបាននោះ សិស្សឯទៀត ឬគ្រូត្រូវចូលរួមបកស្រាយទាល់តែបានច្បាស់។
- សម្របសម្រួលការបកស្រាយ
- ដឹកនាំសិស្សធ្វើការបូកសរុប
- សរសេរការបូកសរុបលើក្តារខៀន

  បូកសរុប៖ ជីដូនជីតា ឪពុកម្តាយ មាមីង ម្តាយធំឪពុកធំ បងប្អូនបង្កើត .... គឺជាញាតិសន្តាន។

សកម្មភាពទី៥៖ ផ្ទៀងផ្ទាត់ការប៉ាន់ស្មាន

- ឱ្យសិស្សផ្ទៀងផ្ទាត់ចម្លើយទៅនឹងការប៉ាន់ស្មាន៖ តើការប៉ាន់ស្មានរបស់យើងត្រឹមត្រូវឬទេ? បើការប៉ាន់ស្មានដូចនឹងចម្លើយក្នុងការស្រាវជ្រាវ យើងនិយាយថា ការប៉ាន់ស្មានត្រូវបានគាំទ្រដោយការស្រាវជ្រាវ។
- លើកសរសើរសិស្សដែលប៉ាន់ស្មានបានត្រឹមត្រូវ។

សកម្មភាពទី៦៖ កសាងមេរៀន

- សួរកពាក្យគន្លឹះ៖ តើប្អូនណាអាចរកពាក្យគន្លឹះនៅក្នុងមេរៀននេះបាន?
- សរសេរពាក្យគន្លឹះលើក្តាខៀន៖ ជីដូនជីតា ឪពុកម្តាយ ញាតិសន្តាន...។
- ឱ្យសិស្សតែងឃ្លាចងចាំ៖ តាមរយៈពាក្យគន្លឹះ ចូរប្អូនសាកល្បងតែងជាឃ្លាចងចាំ ឬគ្រូសួរបំផុសបន្ថែម
- សរសេរឃ្លាចងចាំលើក្តារខៀនដោយឱ្យសិស្សថាតាមតៗគ្នារហូតគ្រូសរសេរចប់

  មេរៀនសង្ខេប៖ ជីដូនជីតា ឪពុកម្តាយ មាមីង ឪពុកធំម្តាយធំ បងប្អូនប្រុសស្រី បងជីដូនមួយ ប្អូនជីដូនមួយ ទាំងអស់នេះ ជាញាតិសន្តាន។

សកម្មភាពទី៧៖ ការដាក់ចំណងជើង

- សួរកចំណងជើងមេរៀនប្រចាំថ្ងៃ៖ តើថ្ងៃនេះយើងរៀនអំពីអ្វី?
- សរសេរចំណងជើងលើក្តារខៀន៖ **ការណែនាំពីញាតិសន្តាន**
- ឱ្យសិស្សអានមេរៀនសង្ខេប។

ផ្នែកទី៣
សណាគប័ត្រជំពូកនិងមេរៀន

ជំពូកទី១

ទម្លាប់ល្អរបស់គ្រួសារខ្ញុំ

រយៈពេល	៦ម៉ោង
វត្ថុបំណងមេរៀន	ប្រាប់ពីផលប្រយោជន៍នៃទម្លាប់ល្អរបស់គ្រួសារខ្ញុំបានត្រឹមត្រូវ។
ចំណងជើងមេរៀន	
មេរៀនទី១	ការណែនាំពីញាតិសន្តាន
មេរៀនទី២	របៀបសំពះ
មេរៀនទី៣	ទង្វើគួរធ្វើ និងទង្វើគួរចៀសវាង

មេរៀនទី១	**ការណែនាំពីញាតិសន្តាន**
រយៈពេល	២ម៉ោង
វត្ថុបំណង	ណែនាំញាតិសន្តានរបស់ខ្លួនទៅកាន់នរណាម្នាក់បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី២ ដល់ទំព័រទី៣ រូបភាព៖ ទំព័រទី២-៣
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រទី៦
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ជីដូន ជីតា ឪពុក ម្តាយ មា មីង ឪពុកធំ ម្តាយធំ បងជីដូនមួយ ប្អូនជីដូនមួយ **លំហាត់ទី២៖** បងជីដូនមួយ ឬប្អូនជីដូនមួយ **លំហាត់ទី៣៖** ចម្លើយតាមការជាក់ស្តែង

មេរៀនទី២	**របៀបសំពះ**
រយៈពេល	២ម៉ោង
វត្ថុបំណង	សំពះបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី៤ ដល់ទំព័រទី៥ រូបភាព៖ ទំព័រទី៤-៥
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រទី៦
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ឃ. ៥បែប **លំហាត់ទី២៖** ក ⇨ ឪពុកម្តាយ ខ ⇨ព្រះសង្ឃ

	លំហាត់ទី៣៖ សិស្សអនុវត្តរបៀបសំពះជាក់ស្តែងនៅក្នុងថ្នាក់។

មេរៀនទី៣	**ទង្វើគួរធ្វើនិងទង្វើគួរចៀសវាង**
រយៈពេល	២ម៉ោង
វត្ថុបំណង	រៀបរាប់ទង្វើល្អនិងទង្វើគួរចៀសវាងបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី៦ ដល់ទំព័រទី៨ រូបភាពទំព័រទី៨
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រទី៦
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ក គ ឃ **លំហាត់ទី២៖** ក គ **លំហាត់ទី៣ ៖** ទង្វើគួរធ្វើទៅមិត្តភក្តិ គឺចេះគោរពគ្នា ស្រឡាញ់រាប់អានគ្នា ចេះជួយគ្នា **លំហាត់ទី៤ ៖** មិនវាយតប់គ្នា

ជំពូកទី២

កន្លែងដែលខ្ញុំរស់នៅ

រយៈពេល	២ម៉ោង
វត្ថុបំណងមេរៀន	ប្រាប់បានពីវត្ថុនៅក្នុងនិងនៅជុំវិញផ្ទះបានត្រឹមត្រូវ។
ចំណងជើងមេរៀន	
មេរៀនទី១	វត្ថុដែលមាននៅក្នុងផ្ទះខ្ញុំ
មេរៀនទី២	វត្ថុដែលមាននៅជុំវិញផ្ទះខ្ញុំ

មេរៀនទី១	**វត្ថុដែលមាននៅក្នុងផ្ទះខ្ញុំ**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់វត្ថុដែលមាននៅក្នុងផ្ទះបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី១០ ដល់ទំព័រទី១២ រូបភាពទំព័រទី១០
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រទី៦
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ក គ **លំហាត់ទី២៖** បន្ទប់ទទួលភ្ញៀវ៖ ក គ ង បន្ទប់ដេក៖ ខ ឆ បន្ទប់ទឹក៖ ឃ ច ផ្ទះបាយ៖ ជ

មេរៀនទី២	**វត្ថុដែលមាននៅជុំវិញផ្ទះខ្ញុំ**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់ពីវត្ថុនៅជុំវិញផ្ទះបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី១៣ ដល់ទំព័រទី១៤ រូបភាពទំព័រទី១៣
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រទី៦
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** មុខផ្ទះ៖ ខ

ក្រោយផ្ទះ៖ ង
ខាងឆ្វេង៖ គ
ខាងស្តាំ៖ ក ឃ
លំហាត់ទី២៖
ដើមដូង ដើមចេក ដើមស្វាយ ដើមស្លឹកគ្រៃ បង្គន់ ពាងទឹក...។
លំហាត់ទី៣៖ (ចម្លើយតាមការដាក់ស្តែង)

ជំពូកទី៣

ការបង្ការគ្រោះថ្នាក់នៅតាមផ្ទះ

រយៈពេល	២ម៉ោង
វត្ថុបំណងមេរៀន	ប្រាប់ពីមូលហេតុនិងវិធីបង្ការគ្រោះថ្នាក់នៅតាមផ្ទះ ជុំវិញផ្ទះបានត្រឹមត្រូវ។
ចំណងជើងមេរៀន	
មេរៀនទី១	គ្រោះថ្នាក់ផ្សេងៗនៅតាមផ្ទះ
មេរៀនទី២	ការបង្ការគ្រោះថ្នាក់

មេរៀនទី១	**គ្រោះថ្នាក់ផ្សេងៗនៅតាមផ្ទះ**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់គ្រោះថ្នាក់ផ្សេងៗនៅតាមផ្ទះបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី១៦ ដល់ទំព័រទី១៨ រូបភាពទំព័រទី១៨
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រទី៦
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ក គ ឃ **លំហាត់ទី២៖** ក. ជំងឺ ខ. គ្រោះថ្នាក់ គ. ពុល **លំហាត់ទី៣៖** ក. រលាក ឆេះផ្ទះ ខ. បាក់ដៃបាក់ជើង បែកក្បាល

មេរៀនទី២	**ការបង្ការគ្រោះថ្នាក់**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់ពីវិធីបង្ការគ្រោះថ្នាក់នៅតាមផ្ទះបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី១៩ ដល់ទំព័រទី២១ រូបភាពទំព័រទី១៩
ដំណើរការបង្រៀន	មើលលំនាំនៃការបង្រៀនទំព័រទី៦
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ក. លេងល្បែងណាដែលមានសុវត្ថិភាព។ ខ. រៀបចំផ្ទះឱ្យស្អាតនិងទុកដាក់ឱ្យមានសណ្តាប់ធ្នាប់។ ឃ. រៀបចំទុកដាក់សម្ភារៈតាមកន្លែងរបស់វា។ **លំហាត់ទី២៖** ក. រៀបចំ ខ. នាំឱ្យធ្លាក់ គ. ទុកដាក់ **លំហាត់ទី៣៖** ខ គ ឃ

ជំពូកទី៤

កិច្ចការប្រចាំថ្ងៃរបស់ខ្ញុំ

រយៈពេល	៩ម៉ោង
វត្ថុបំណងមេរៀន	ប្រាប់ពីកិច្ចការនៅផ្ទះនិងនៅសាលារៀនបានត្រឹមត្រូវ។
ចំណងជើងមេរៀន	
មេរៀនទី១	មុនពេលទៅសាលារៀន
មេរៀនទី២	កិច្ចការខ្ញុំនៅសាលារៀន
មេរៀនទី៣	កិច្ចការខ្ញុំនៅផ្ទះ
មេរៀនទី៤	កូនល្អ សិស្សល្អ មិត្តល្អ
មេរៀនទី៥	ខ្ញុំចូលចិត្ត និងមិនចូលចិត្ត

មេរៀនទី១	**មុនពេលទៅសាលារៀន**
រយៈពេល	២ម៉ោង
វត្ថុបំណង	ប្រាប់ពីកិច្ចការដែលត្រូវធ្វើមុនពេលទៅសាលារៀនបានត្រឹមត្រូវ។
សម្ភារៈបង្រៀន	ស.ស. ទំព័រទី២៣ ដល់ទំព័រ២៤ រូបភាព៖ ទំព័រទី២៣-២៤
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រទី៦
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ដាក់លេខរៀងតាមលំដាប់សកម្មភាព៖ ១.ង ២.គ ៣.ច ៤.ក ៥.ខ ៦.ឃ **លំហាត់ទី២៖** ក. បត់ភួយ ដុសធ្មេញ សម្អាតខ្លួនប្រាណ ខ. ទៅសាលារៀន **លំហាត់ទី៣៖** ក. ជម្រាបលា ខ. ប៉ា! ម៉ាក់! កូនជម្រាបលាទៅសាលារៀនហើយ។

មេរៀនទី២	**កិច្ចការខ្ញុំនៅសាលារៀន**
រយៈពេល	២ម៉ោ
វត្ថុបំណង	ប្រាប់ពីកិច្ចការនៅសាលារៀនបានត្រឹមត្រូវ។
សម្ភារៈបង្រៀន	ស.ស. ទំព័រទី២៥ ដល់ទំព័រទី២៧ រូបភាព៖ ទំព័រទី២៥-២៦-២៧
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រទី៦

ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ក គ **លំហាត់ទី២៖** ខ គ ឃ ង **លំហាត់ទី៣៖** ក. គោរពទង់ជាតិ ខ. ជម្រាបសួរលោកគ្រូ អ្នកគ្រូ គ. ដើម្បីសួរលោកគ្រូអ្នកគ្រូ ឃ. មានអនាម័យ **លំហាត់ទី៤៖** ដើម្បីឱ្យក្លាយជាសិស្សល្អ ត្រូវខិតខំរៀនសូត្រ គោរពវិន័យ និងចូលរួមធ្វើការងារសាលា ។

មេរៀនទី៣	**កិច្ចការខ្ញុំនៅផ្ទះ**
រយៈពេល	១ម៉ោង
វត្ថុបំណង	ប្រាប់ពីកិច្ចការនៅផ្ទះបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី២៨ ដល់ទំព័រទី៣០ រូបភាពទំព័រទី២៨
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រទី៦
	លំហាត់ទី១៖ ខ ឃ **លំហាត់ទី២៖** នៅផ្ទះ ខ្ញុំ... ⇨ ក ខ គ **លំហាត់ទី៣៖** ចម្លើយតាមការជាក់ស្តែង

មេរៀនទី៤	**កូនល្អ សិស្សល្អ មិត្តល្អ**
រយៈពេល	២ម៉ោង
វត្ថុបំណង	ប្រាប់ពីសកម្មភាពរបស់កូនល្អ សិស្សល្អ មិត្តល្អបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី៣១ ដល់ទំព័រទី៣២ រូបភាពទំព័រទី៣១
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៦
	លំហាត់ទី១៖ កូនល្អ ⇨ គ ង ច ជ សិស្សល្អ ⇨ ក ឆ ឈ មិត្តល្អ ⇨ ខ ឃ **លំហាត់ទី២៖** (១)ក្រោក (២)យឺតយ៉ាវ (៣)ស្រស់ស្រូប (៤)ទុក (៥)រាយប៉ាយ (៦)ចេញដំណើរ (៧)ធ្វើ (៨)ជម្រាប (៩)មាតាបិតា (១០)ជ្រាប

មេរៀនទី៥	**ខ្ញុំចូលចិត្តនិងមិនចូលចិត្ត**
រយៈពេល	២ម៉ោង

វត្ថុបំណង	ប្រាប់ពីសកម្មភាពដែលចូលចិត្តនិងមិនចូលចិត្តបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី៣៣ ដល់ទំព័រទី៣៥ រូបភាព៖ ទំព័រទី៣៣-៣៤-៣៥
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រទី៦
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** សកម្មភាពដែលផ្តល់ប្រយោជន៍៖ ក ខ សកម្មភាពដែលផ្តល់គ្រោះថ្នាក់៖ ខ ឃ **លំហាត់ទី២៖** ចូលចិត្ត៖ ក គ មិនចូលចិត្ត៖ ខ ឃ **លំហាត់ទី៣៖** ក. ជក់បារី ខ. ហាត់ប្រាណ

ជំពូកទី៥

ទម្លាប់ល្អនៅសាលារៀនខ្ញុំ

រយៈពេល	២ម៉ោង
វត្ថុបំណងមេរៀន	ប្រាប់បានពីទម្លាប់ល្អនៅសាលារៀនបានត្រឹមត្រូវ។
ចំណងជើងមេរៀន	
មេរៀនទី១	ទម្លាប់ល្អក្នុងនិងក្រៅថ្នាក់រៀន
មេរៀនទី២	ទម្លាប់មិនល្អនៅក្នុងនិងក្រៅថ្នាក់រៀន

មេរៀនទី១	**ទម្លាប់ល្អក្នុងនិងក្រៅថ្នាក់រៀន**
រយៈពេល	១ម៉ោង
វត្ថុបំណង	ប្រាប់បានពីទម្លាប់ល្អក្នុងនិងក្រៅថ្នាក់បានត្រឹមត្រូវ។
សម្ភារៈបទេស	ស.ស. ទំព័រទី៣៧ ដល់ទំព័រទី៣៩ រូបភាពទំព័រទី៣៧
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រទី៦
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ក ឃ **លំហាត់ទី២៖** ក ឃ **លំហាត់ទី៣៖** សកម្មភាពដែលបង្ហាញពីទម្លាប់ល្អនៅក្នុងនិងក្រៅថ្នាក់រៀនគឺ ៖ ខ. យើងលេងល្បែងណាដែលមានសុវត្ថិភាព។ គ. យើងមិនបង្កជម្លោះ។ ង. យើងចោលកាកសំណល់ផ្សេងៗក្នុងធុងសំរាម។ ឆ. យើងចូលរួមគ្រប់សកម្មភាពទាំងអស់របស់សាលារៀន។ **លំហាត់ទី៤៖** ចម្លើយតាមការជាក់ស្តែង

មេរៀនទី២	**ទម្លាប់មិនល្អក្នុងនិងក្រៅថ្នាក់រៀន**
រយៈពេល	១ម៉ោង
វត្ថុបំណង	ប្រាប់បានពីទម្លាប់មិនល្អនៅក្នុងនិងក្រៅថ្នាក់បានត្រឹមត្រូវ។
សម្ភារៈបទេស	ស.ស. ទំព័រទី៤០ ដល់ទំព័រទី៤២ រូបភាពទំព័រទី៤០

ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រទី៦
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ក គ ឃ **លំហាត់ទី២៖** ក គ ឃ **លំហាត់ទី៣៖** សកម្មភាពដែលត្រូវចៀសវាង៖ ខ. បង្កជម្លោះ គ. លេង ឬជជែកគ្នាពេលគ្រូពន្យល់ ង. លេងវាយតប់គ្នា ច. គេងក្នុងម៉ោងរៀន **លំហាត់ទី៤៖** ទម្លាប់មិនល្អនៅក្នុងនិងក្រៅថ្នាក់ផ្តល់ផលវិបាកដូចជា មិនសូវមានមិត្តភក្តិ រៀនសូត្រមិនបានពូកែ មានគ្រោះថ្នាក់ដល់រាងកាយ...។

ជំពូកទី៦

ចម្រៀងនិងការកម្សាន្ត

រយៈពេល	៣ម៉ោង
វត្ថុបំណងមេរៀន	ច្រៀងបទនគររាជនិងរៀបរាប់ពីឧបករណ៍ភ្លេងបុរាណបានត្រឹមត្រូវ។
ចំណងជើងមេរៀន	
មេរៀនទី១	ភ្លេងជាតិ
មេរៀនទី២	វង់ភ្លេង
មេរៀនទី៣	របៀបបត់ ឬកាត់ក្រដាស

មេរៀនទី១	**ភ្លេងជាតិ**
រយៈពេល	១ម៉ោង
វត្ថុបំណង	ច្រៀងបទនគររាជបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី៤៤ ដល់ទំព័រទី៤៥ រូបភាព៖ ទំព័រទី៤៤-៤៥
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រទី៦
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ខ. បទនគររាជ **លំហាត់ទី២៖** គ. គោរពទង់ជាតិ

មេរៀនទី២	**វង់ភ្លេង**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់ពីឧបករណ៍ភ្លេងបុរាណនិងសម័យបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី៤៦ ដល់ទំព័រទី៤៩ រូបភាព៖ ទំព័រទី៤៦-៤៧
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រទី៦
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ក គ **លំហាត់ទី២៖** ខ ឃ **លំហាត់ទី៣៖**

ឧបករណ៍	ផ្លុំ	កូត	ដេញ	វាយ	គោះដំ
រនាត					√

	ខ្ចុយ	√				
	ទ្រ		√			
	ស្តរ				√	
	តារេខ			√		

មេរៀនទី៣	**របៀបបត់ ឬកាត់ក្រដាស**
រយៈពេល	១ម៉ោង
វត្ថុបំណង	ប្រាប់របៀបត់ ឬកាត់ក្រដាសបានត្រឹមត្រូវ។
សម្ភារៈបទេស	ស.ស. ទំព័រទី៥០ ដល់ទំព័រទី៥២ រូបភាព៖ ទំព័រ៥១-៥២ សម្ភារៈ៖ ក្រដាស ការ៉ កន្ត្រៃ បន្ទាត់ ខ្មៅដៃ
ដំណើរការបង្រៀន	សូមអនុវត្តតាមលេខរៀងនិងគំនូសព្រួញនៅលើរូបភាពនីមួយៗក្នុងសៀវភៅសិស្ស
ចម្លើយ/កំណែលំហាត់	លំហាត់ទី១និងទី២ អនុវត្តតាមសៀវភៅសិស្សទំព័រ៥២

ជំពូកទី៧

សុវត្ថិភាពក្នុងការធ្វើដំណើរ

រយៈពេល	១០ម៉ោង
វត្ថុបំណងមេរៀន	ប្រាប់ពីបម្រុងប្រយ័ត្នក្នុងការធ្វើដំណើរបានត្រឹមត្រូវ។
ចំណងជើងមេរៀន	
មេរៀនទី១	ការបង្ការគ្រោះថ្នាក់នៅតាមដងផ្លូវ
មេរៀនទី២	របៀបឆ្លងផ្លូវមានភ្លើងសញ្ញានិងគំនូសនៅលើផ្លូវថ្នល់
មេរៀនទី៣	របៀបឆ្លងផ្លូវគ្មានភ្លើងសញ្ញានិងគ្មានគំនូសនៅលើផ្លូវថ្នល់
មេរៀនទី៤	ភ្លើងសញ្ញាចរាចរណ៍និងស្លាកសញ្ញាចរាចរណ៍
មេរៀនទី៥	ការធ្វើដំណើរប្រកបដោយសុវត្ថិភាព

មេរៀនទី១	**ការបង្ការគ្រោះថ្នាក់នៅតាមដងផ្លូវ**
រយៈពេល	២ម៉ោង
វត្ថុបំណង	ប្រាប់ពីវិធីប្រុងប្រយ័ត្នគ្រប់សកម្មភាពនៅពេលធ្វើដំណើរបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី៥៤ ដល់ទំព័រទី៥៥ រូបភាព៖ ទំព័រទី៥៤-៥៥
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រទី៦
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ខ ឃ ច **លំហាត់ទី២៖** បម្រុងប្រយ័ត្ននៅពេលធ្វើដំណើរ ⇨ ក គ ឃ ង

មេរៀនទី២	**របៀបឆ្លងផ្លូវមានភ្លើងសញ្ញានិងគំនូសនៅលើផ្លូវថ្នល់**
រយៈពេល	២ម៉ោង
វត្ថុបំណង	ប្រាប់ពីរបៀបឆ្លងផ្លូវមានភ្លើងសញ្ញានិងគំនូសនៅលើផ្លូវថ្នល់បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី៥៦ ដល់ទំព័រទី៥៨ រូបភាព៖ ទំព័រទី៥៦-៥៧
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រទី៦
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ភ្លើងក្រហម ⇨ ក ភ្លើងបៃតង ⇨ ខ

	គំនូសកាត់ទទឹងផ្លូវ ⇨ ឃ គំនូសសតាមបណ្តោយផ្លូវ ⇨ គ **លំហាត់ទី២៖** ក. ពណ៌ស ខ. ភ្លើងពណ៌បៃតងមានមនុស្សដើរ គ. ឆ្លងតាមគំនូសពណ៌សកាត់ទទឹងទ្រូងផ្លូវ

មេរៀនទី៣	**របៀបឆ្លងផ្លូវគ្មានភ្លើងសញ្ញានិងគ្មានគំនូសនៅលើផ្លូវថ្នល់**
រយៈពេល	២ម៉ោង
វត្ថុបំណង	ប្រាប់ពីរបៀបឆ្លងផ្លូវគ្មានភ្លើងសញ្ញានិងគ្មានគំនូសនៅលើផ្លូវថ្នល់បានត្រឹមត្រូវ។
សម្ភារៈបង្រៀន	ស.ស.ទំព័រទី៥៨ ដល់ទំព័រទី៦០ រូបភាពៈទំព័រទី៥៩-៦០
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រទី៦
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ១ ៤ ៥ ៦ **លំហាត់ទី២៖** ដាក់លេខរៀងតាមលំដាប់សកម្មភាព ១. គ ២. ក ៣. ខ **លំហាត់ទី៣៖** ក. ៣ដំណាក់ ខ. ឈរចាំពេលដែលអាចឆ្លងបាន រួចដើរឆ្លងដោយមើលឆ្វេងស្តាំ

មេរៀនទី៤	**ភ្លើងសញ្ញាចរាចរណ៍និងស្លាកសញ្ញាចរាចរណ៍**
រយៈពេល	២ម៉ោង
វត្ថុបំណង	ប្រាប់ពីភ្លើងសញ្ញាចរាចរណ៍និងស្លាកសញ្ញាចរាចរណ៍បានត្រឹមត្រូវ។
សម្ភារៈបង្រៀន	ស.ស.ទំព័រទី៦២ ដល់ទំព័រទី៦៣ រូបភាពៈទំព័រទី៦២
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រទី៦
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ភ្លើងសញ្ញាចរាចរណ៍សម្រាប់ថ្មើរជើង៖ គ ភ្លើងសញ្ញាចរាចរណ៍មាន៖ ខ. បីពណ៌ **លំហាត់ទី២៖** ក ⇨ គ្រប់យានជំនិះត្រូវឈប់ ខ ⇨ គ្រប់យានជំនិះត្រូវប្រុងប្រយ័ត្ន

	គ ⇨ គ្រប់យានជំនិះអាចធ្វើដំណើរបាន **លំហាត់ទី៣៖** ក. ហាមដើរឆ្លងកាត់ ខ. ថ្មើរជើងឆ្លងកាត់ គ. ហាមចូល

មេរៀនទី៥	**ការធ្វើដំណើរប្រកបដោយសុវត្ថិភាព**
រយៈពេល	២ម៉ោង
វត្ថុបំណង	ប្រាប់ពីរបៀបធ្វើដំណើរប្រកបដោយសុវត្ថិភាពបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស.ទំព័រទី៦៤ ដល់ទំព័រទី៦៦ រូបភាពទំព័រទី៦៤
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រទី៦
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** បំពាន ⇨ ខ គ ត្រូវ ⇨ ក ឃ **លំហាត់ទី២៖** ក ខ ឃ ង

ជំពូកទី៨

សុវត្ថិភាពក្នុងការលេងទឹក

រយៈពេល	៤ម៉ោង
វត្ថុបំណងមេរៀន	ប្រាប់ពីប្រុងប្រយ័ត្នក្នុងការលេងល្បែងផ្សេងៗបានត្រឹមត្រូវ។
ចំណងជើងមេរៀន	
មេរៀនទី១	ល្បែងផ្សេងៗរបស់កុមារ
មេរៀនទី២	សុវត្ថិភាពក្នុងការលេងទឹក

មេរៀនទី១	**ល្បែងផ្សេងៗរបស់កុមារ**
រយៈពេល	២ម៉ោង
វត្ថុបំណង	រៀបរាប់ពីល្បែងផ្សេងៗរបស់កុមារបានត្រឹមត្រូវ។
សម្ភារៈបង្ហាត់	ស.ស.ទំព័រទី៦៨ ដល់ទំព័រទី៦៩ រូបភាពទំព័រទី៦៨
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រទី៦
ចម្លើយនៃសំណួរ	១. ទាត់សី លោតមឹក លេងបាល់ ទាត់បាល់ លោតអន្ទាក់ ២. លេងបាយខុំ លោតមឹក លេងត្រែ ៣. ចម្លើយតាមការជាក់ស្តែង
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ខ. លោតទឹក គ. ឡើងដើមឈើ **លំហាត់ទី២៖** ក. លាក់កន្សែង ខ. ទាត់សី **លំហាត់ទី៣៖** នៅសាលារៀន កុមារចូលចិត្តលេងទាត់សី លោតមឹក លេងបាល់.....។ នៅផ្ទះកុមារចូលចិត្តលេង៖ បង្ហោះខ្លែង លេងបាល់.....។ (ចម្លើយអាចមានផ្សេងពីនេះ)

មេរៀនទី២	**សុវត្ថិភាពក្នុងការលេងទឹក**
រយៈពេល	២ម៉ោង
វត្ថុបំណង	ប្រាប់វិធីលេងទឹកដើម្បីឱ្យមានសុវត្ថិភាពបានត្រឹមត្រូវ។
សម្ភារៈបង្ហាត់	ស.ស.ទំព័រទី៧០ ដល់ទំព័រទី៧១ រូបភាព៖ទំព័រទី៧០-៧១

ជំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រទី៦
ចម្លើយនៃសំណួរ	១. កុមារចូលចិត្តលេងទឹកស្រះ បឹង អូរ ប្រឡាយ ព្រែក ទន្លេ។ ២. ដើម្បីចៀសវាងគ្រោះថ្នាក់ផ្សេងៗ នៅពេលលេងទឹក ខ្ញុំត្រូវប្រើប្រាស់អាវពោង ឬកង់ឡាន។ ៣. បើមានកុមារណាម្នាក់លង់ទឹក ខ្ញុំត្រូវស្រែកហៅឱ្យគេជួយ។ (ចម្លើយអាចមានផ្សេងពីនេះ)
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ក. ហាមហែលទឹកលេង ខ. ហាមលោតទឹកលេង គ. ហាមប្រឡែងគ្នានៅជិតមាត់ទឹក **លំហាត់ទី២៖** (១)គ្រោះថ្នាក់ (២)អាវសុវត្ថិភាព (៣)ពោះវៀនកង់ឡាន (៤)ដើមឫស្សី (៥)ច្រាំង (៦)មិនចេះ (៧)ទៅធ្លាយ

ជំពូកទី៩

ចៀសវាងការគំរាមកំហែង

រយៈពេល	៦ម៉ោង
វត្ថុបំណងមេរៀន	ប្រាប់បានពីមធ្យោបាយដើម្បីគេចផុតពីការគំរាមកំហែងបានត្រឹមត្រូវ។
ចំណងជើងមេរៀន	
មេរៀនទី១	ស្ថានភាពមានសុវត្ថិភាព
មេរៀនទី២	ការចៀសវាងពីស្ថានភាពគ្មានសុវត្ថិភាព
មេរៀនទី៣	របៀបទាក់ទងជាមួយអ្នកការពារ

មេរៀនទី១	**ស្ថានភាពមានសុវត្ថិភាព**
រយៈពេល	២ម៉ោង
វត្ថុបំណង	ប្រាប់ស្ថានភាពដែលមានសុវត្ថិភាពបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី៧៣ ដល់ទំព័រទី៧៦ រូបភាព៖ ទំព័រទី៧៣-៧៤-៧៥
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រទី៦
ចម្លើយសំណួរ	១. ខ្ញុំមានសុខភាពល្អ ព្រោះខ្ញុំមានអាហារញ៉ាំគ្រប់គ្រាន់។ ២. ខ្ញុំបានសប្បាយរីករាយ ព្រោះបានរស់នៅជួបជុំគ្រួសារ មានឱកាសបានរៀនសូត្រ និងមានមិត្តភក្តិចេះជួយគ្នាទៅវិញទៅមក។ ៣. ខ្ញុំមានទំនាក់ទំនងល្អជាមួយឪពុកម្តាយ បងប្អូន សមាជិកគ្រួសារផ្សេងទៀត និងមិត្តភក្តិ។
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ក គ ច **លំហាត់ទី២៖** ខ ឃ **លំហាត់ទី៣៖** ក. មានឪពុកម្តាយ និងបានរៀនសូត្រ ខ. ខ្ញុំកំព្រានិងមិនបានរៀនសូត្រ **លំហាត់ទី៤៖** ខ. ខ្ញុំបានរៀនសូត្រ

មេរៀនទី២	**ការចៀសវាងអំពើបង្ខិតបង្ខំ**
រយៈពេល	២ម៉ោង

វត្ថុបំណង	ប្រាប់វិធីចៀសវាងពីអំពើបង្ខិតបង្ខំបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស.ទំព័រទី៧៧ ដល់ទំព័រទី៧៨
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រទី៦
ចម្លើយសំណួរ	១. ជនខិលខូចប្រើកលល្បិចលួងលោមដូចជា៖ - មក!ពូជូនពួកឯងទៅផ្ទះ។ - ពួកឯងទៅតាមខ្ញុំទៅ ឯងនឹងបានលុយច្រើន។ ជនខិលខូចធ្វើដូច្នេះ ដើម្បីបោកបញ្ឆោតនិងអូសទាញយកផលប្រយោជន៍ពីកុមារ។ ២. ឆ្លើយថា «ទេ» ឬស្រែកឱ្យគេជួយ និងទៅប្រាប់សមត្ថកិច្ច។
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ក. យកទៅលក់ ឬជួញដូរផ្លូវភេទ - ជួញដូរកម្លាំងពលកម្ម ខ. ស្តាប់ដំបូន្មានឪពុកម្តាយ - ស្រែកថា «ទេ» រាល់ការលួងលោម **លំហាត់ទី២៖** (១)ហិង្សា (២)រាងកាយ (៣)អារម្មណ៍ (៤)បំបាត់ (៥)ប្រព្រឹត្ត (៦)របួសស្នាម

មេរៀនទី៣	**អ្នកជួយការពារ**
រយៈពេល	២ម៉ោង
វត្ថុបំណង	ប្រាប់ពីរបៀបទាក់ទងជាមួយអ្នកការពារបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី៧៩ ដល់ទំព័រទី៨១ រូបភាព៖ ទំព័រទី៧០-៨០-៨១
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៦
ចម្លើយសំណួរ	១. លោកគ្រូ អ្នកគ្រូ លោកនាយកសាលា ឪពុកម្តាយ ចាស់ទុំ ឬនគរបាល ២. ដើម្បីការពារខ្លួនពីស្ថានភាពគ្មានសុវត្ថិភាពផ្សេងៗ ៣. ត្រូវនិយាយផ្ទាល់មាត់ សរសេរជាសំបុត្រ ឬទូរស័ព្ទ នៅពេលដែលយើងឃើញ ឬជួបនឹងគ្រោះថ្នាក់។ ៤. ទៅហៅដោយផ្ទាល់ ឬទូរស័ព្ទហៅ។
ចម្លើយ/កំណែលំហាត់	**លំហាត់៖** នគរបាល

ជំពូកទី១០

ទីតាំងសាលារៀននិងភូមិ

រយៈពេល	៤ម៉ោង
វត្ថុបំណងមេរៀន	បង្ហាញទីតាំងសាលារៀននិងភូមិបានត្រឹមត្រូវ។
ចំណងជើងមេរៀន	
មេរៀនទី១	កន្លែងសំខាន់ៗនៅភូមិខ្ញុំ
មេរៀនទី២	គូរផែនទីបង្ហាញទីតាំងសាលារៀន

មេរៀនទី១	**កន្លែងសំខាន់ៗនៅភូមិខ្ញុំ**
រយៈពេល	២ម៉ោង
វត្ថុបំណង	រៀបរាប់កន្លែងសំខាន់ៗនៅក្នុងភូមិបានត្រឹមត្រូវ។
សម្ភារៈបង្រៀន	ស.ស. ទំព័រទី៨៣ ដល់ទំព័រទី៨៤ រូបភាពទំព័រទី៨៣
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រទី៦
ចម្លើយសំណួរ	១. មាន ផ្ទះ ពេទ្យ ផ្សារ សាលារៀន សាលាឃុំ វត្ត ប្រភពទឹក។ ២. ខ្ញុំស្រឡាញ់ភូមិរបស់ខ្ញុំណាស់ ព្រោះជាទីកន្លែងដែលផ្តល់សេចក្តីសុខដល់ប្រជាជន។
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ក. សាលារៀន គ. មន្ទីរពេទ្យ ឃ. សាលាឃុំ ង. វត្តអារាម **លំហាត់ទី២៖** ក. ដើម្បីការពារញឹមនៃកុមារ ខ. ភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ (ចម្លើយអាចមានផ្សេងពីនេះ) គ. វត្ត ផ្សារ សាលារៀន មន្ទីរពេទ្យ សាលាឃុំ

មេរៀនទី២	**គូរផែនទីបង្ហាញទីតាំងសាលារៀន**
រយៈពេល	២ម៉ោង
វត្ថុបំណង	គូរផែនទីសាលារៀនបានត្រឹមត្រូវ។
សម្ភារៈបង្រៀន	ស.ស. ទំព័រទី៨៥ ដល់ទំព័រទី៨៦ រូបភាពទំព័រទី៨៥
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រទី៦
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ក. កំណត់ទីតាំងដែលត្រូវបង្ហាញ គ. កំណត់កន្លែងសំខាន់ៗនៅជុំវិញ

លំហាត់ទី២៖

ទីតាំងសាលារៀន៖ សាលារៀននេះ ស្ថិតនៅជាប់ថ្នល់ជាតិ។ នៅខាងស្តាំ មានផ្លូវលំតូចមួយនិងផ្ទះប្រជាជន។ នៅខាងក្រោយមានវត្តនិងផ្ទះប្រជាជន។

ទីតាំងវត្ត៖ វត្តស្ថិតនៅខាងក្រោយសាលារៀន ខណ្ឌដោយផ្លូវលំមួយ។ នៅខាងស្តាំមានផ្លូវលំតូចមួយនិងផ្ទះប្រជាជន។ នៅខាងឆ្វេងមានផ្លូវលំនិងវាលស្រែ។ ខាងក្រោយវត្តជាប់ទៅដោយវាលស្រែ។

លំហាត់ទី៣៖ គូរតាមភាពជាក់ស្តែង

លំហាត់ទី៤៖ គូរតាមភាពជាក់ស្តែង

ជំពូកទី១១

ប្រវត្តិសាលារៀននិងភូមិខ្ញុំ

រយៈពេល	៨ម៉ោង
វត្ថុបំណងមេរៀន	ពណ៌នាពីប្រវត្តិសាលារៀននិងភូមិបានត្រឹមត្រូវ។
ចំណងជើងមេរៀន	
មេរៀនទី១	ប្រវត្តិសាលារៀនខ្ញុំ
មេរៀនទី២	ប្រវត្តិភូមិខ្ញុំ
មេរៀនទី៣	ប្រវត្តិសង្កាត់ខ្ញុំ(សង្កាត់ព្រែកព្នៅ)
មេរៀនទី៤	ការថែរក្សាបរិស្ថានសាលារៀន

មេរៀនទី១	**ប្រវត្តិសាលារៀនខ្ញុំ**
រយៈពេល	២ម៉ោង
វត្ថុបំណង	ពណ៌នាពីប្រវត្តិសាលារៀនបានត្រឹមត្រូវ។
សម្ភារៈបង្រៀន	ស.ស. ទំព័រទី៨៨ ដល់ទំព័រទី៨៩ រូបភាពទំព័រទី៨៨
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រទី៦
ចម្លើយសំណួរ	១. សង្កាត់ព្រែកព្នៅ ២. នៅក្រោយឆ្នាំ១៩៧៩ ៣. មានពីរខ្នង
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** (១)ដើម្បីភាពញញឹមនៃកុមារ (២)ភូមិទ្រា (៣)សង្កាត់ស្ទឹងមានជ័យ (៤)ខ័ណ្ឌមានជ័យ (៥)ភ្នំពេញ (៦)២ (៧)១០ (ចម្លើយអាចមានផ្សេងពីនេះ) **លំហាត់ទី២៖** ចម្លើយទៅតាមការដាក់ស្តែង

មេរៀនទី២	**ប្រវត្តិភូមិខ្ញុំ**
រយៈពេល	២ម៉ោង
វត្ថុបំណង	ពណ៌នាពីប្រវត្តិភូមិបានត្រឹមត្រូវ។
សម្ភារៈបង្រៀន	ស.ស. ទំព័រទី៩០ ដល់ទំព័រទី៩១ រូបភាពទំព័រទី៩០

ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រទី៦
ចម្លើយសំណួរ	១. ផ្លូវជាតិលេខ៥ សង្កាត់ព្រែកហ្នៅ ខណ្ឌព្រែកហ្នៅ ២. ព្រោះកាលដើមឡើយ ទីនោះ មានតែគ្រួសារតាឪងមួយប៉ុណ្ណោះ។ ក្រោយមក ទើបមានប្រជាជនមករស់នៅជាបន្តបន្ទាប់។ ដោយយល់ថា តាឪងជាចាស់ព្រឹទ្ធាចារ្យនៅទីនោះ ទើបប្រជាជនទាំងអស់នាំគ្នាហៅទីនោះថា «ភូមិតាឪង» ប៉ុន្តែឥឡូវនេះ គេហៅថា «ភូមិឪង» ។ ៣. ១៧គីឡូម៉ែត្រ
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ក. ឈ្មោះភូមិ ឃុំ ឬសង្កាត់ ក្រុង ស្រុក ឬខណ្ឌ រាជធានី ឬខេត្ត គ. ប្រវត្តិខ្លះៗរបស់ភូមិនោះ **លំហាត់ទី២៖** ចម្លើយតាមការជាក់ស្តែង

មេរៀនទី៣	**ប្រវត្តិសង្កាត់ខ្ញុំ (សង្កាត់ព្រែកហ្នៅ)**
រយៈពេល	២ម៉ោង
វត្ថុបំណង	ពណ៌នាពីប្រវត្តិឃុំ ឬសង្កាត់បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស.ទំព័រទី៩២ ដល់ទំព័រទី៩៣ រូបភាពទំព័រទី៩២
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៦
ចម្លើយសំណួរ	១. ផ្លូវជាតិលេខ៥ ២. ចម្ងាយ ១៧គីឡូម៉ែត្រ ៣. ព្រោះកាលពីមុននៅទីនោះ មានព្រែកមួយដែលមានឈ្មោះថា «ព្រែកតាហ្នៅ»។ លុះក្រោយមក អ្នកស្រុកហៅ ត្រឹមតែព្រែកហ្នៅៗ តែប៉ុណ្ណោះ។
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** (១)ព្រែកហ្នៅ (២)លេខ៥ (៣)១៧គ.ម (៤)វត្តភ្នំ **លំហាត់ទី២៖** ចម្លើយតាមការជាក់ស្តែង

មេរៀនទី៤	**ការថែរក្សាបរិស្ថានសាលារៀន**
រយៈពេល	២ម៉ោង
វត្ថុបំណង	ប្រាប់ពីការថែរក្សាបរិស្ថានសាលារៀនបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រ៩៤ ដល់ទំព័រ៩៥ រូបភាពទំព័រទី៩៤
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រទី៦
ចម្លើយសំណួរ	១. យើងទាំងអស់គ្នា ត្រូវបោសសម្អាត បង្កើតវេនសម្អាត ធ្វើរបង និងដីករណ្តៅសម្រាប់

	ដាក់សំរាម។ ២. ដើម្បីឱ្យបរិស្ថានសាលារៀនស្អាតនិងមានអនាម័យ ។
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** សកម្មភាពសម្អាតក្នុងថ្នាក់ដូចជា បោសសម្អាតថ្នាក់ ជូតតុ លុបក្តារខៀន...។ សកម្មភាពសម្អាតក្រៅថ្នាក់ដូចជា ជម្រះស្មៅ បោសសម្អាតទីធ្លា...។ **លំហាត់ទី២៖** (១)ស្អាត (២)កាកសំណល់ (៣)ទឹកដក់ (៤)សម្អាត (៥)ដើមឈើ (៦)ដំណាំ (៧)ចូល (៨)បន្លែ

ជំពូកទី១២

ខ្ទុំហាត់រាំ

រយៈពេល	៤ម៉ោង
វត្ថុបំណងមេរៀន	រាំចង្វាក់រាំវង់បែបទី១ បានត្រឹមត្រូវ។
ចំណងជើងមេរៀន	
មេរៀនទី១	លំហាត់ពត់ដៃ ពត់ជើង
មេរៀនទី២	ចង្វាក់រាំវង់បែបទី១

មេរៀនទី១	**លំហាត់ពត់ដៃ ពត់ជើង**
រយៈពេល	២ម៉ោង
វត្ថុបំណង	ពត់ដៃពត់ជើងបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រ៩៧ ដល់ទំព័រ៩៨ រូបភាព៖ ទំព័រទី៩៧-៩៨
ដំណើរការបង្រៀន	មុននឹងចាប់ផ្តើមហាត់ គ្រូត្រូវរៀបចំទីកន្លែង សម្លៀកបំពាក់ឱ្យបានសមរម្យទាំងគ្រូទាំងសិស្ស។ **ការសង្កេតនិងសំណួរបំផុស** សិស្សសង្កេតផ្ទាំងរូបភាព ឬគ្រូអនុវត្តបង្ហាញ - តើរូបភាពនេះបង្ហាញពីអ្វី? - ការអង្គុយរបស់ប្អូន និងការអង្គុយក្នុងផ្ទាំងគំនូរខុសគ្នាដូចម្តេច? - ឥឡូវប្អូនសង្កេតផ្ទាំងរូបភាពនេះ ឡើងវិញឱ្យល្អិតល្អន់ ហើយរៀបរាប់ឡើងវិញអំពីការអង្គុយនេះ។ - ប្អូនសង្កេតលើផ្ទាំងរូបភាពនេះទៀត តើគេបង្ហាញពីអ្វី? - ប្រៀបធៀបអំពីការអង្គុយបត់ជើង ពត់កដៃ និងអង្គុយជៀវជើង។
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ក. រាងកាយមាំមួន ទន់ភ្លន់នឹងនរ ខ. ៤វគ្គ **លំហាត់ទី២៖** ក. ជង្គង់ ខ. ស្តាំ លើ គ. ចន្លោះ ឃ. ដៃ

<u>ព័ត៌មានជំនួយ៖</u>

វគ្គទី១៖

- **អង្គុយបត់ជើង ពត់កដៃ**

គ្រូអនុវត្តផ្ទាល់ជាគំរូ បង្ហាញសិស្សៈ



ក. អង្គុយបត់ជើងឆ្វេង

- ជើងស្តាំគងលើជើងឆ្វេង
- ដៃឆ្វេង ដៃស្តាំ ដាក់ស្របលើភ្លៅស្តាំ
- ដងខ្លួនងើបត្រង់ ក្អែកសម្លឹងទៅមុខ ស្មាបើកទម្លាក់ចុះ
- ប្រឹងចង្កេះនិងម្រាមជើង។ (រូបទី១)

ខ. លំហាត់ពត់កដៃឆ្វេង

- កែងដៃឆ្វេងដាក់លើភ្លៅឆ្វេង
- ជើងស្តាំបត់ ជង្គង់គងលើជើងឆ្វេង
- កែងដៃស្តាំ ដាក់លើជង្គង់ស្តាំ
- ដៃស្តាំចាប់ពត់ប្រអប់ដៃឆ្វេង
- ផ្អៀងចង្កេះឆ្វេង ដងខ្លួន ក្បាលស្របចង្កេះផ្អៀង។

របៀបប្តូរ : (ប្តូរពីឆ្វេងមកស្តាំ)

- ទាញជើងឆ្វេងឱ្យខិតចូលបន្តិច (មើលរូបទី២) ដៃទាំងពីរត្រង់ទៅមុខ
- បង្វិលជើងបត់មកស្តាំវិញ (មើលរូបទី៣)
- អង្គុយបត់ជើងស្តាំ ជើងឆ្វេងគងលើជើងស្តាំ។



(រូបទី២) (រូបទី៣)

គ. លំហាត់ពត់កដៃស្តាំ

- កែងដៃស្តាំ ដាក់លើភ្លៅស្តាំ
- ជើងឆ្វេងបត់ ជង្គង់គងលើជើងស្តាំ
- កែងដៃឆ្វេង ដាក់លើជង្គង់ឆ្វេង។
- ដៃឆ្វេងចាប់ពត់ប្រអប់ដៃស្តាំ
- ផ្អៀងចង្កេះស្តាំ ដងខ្លួន ក្បាល ស្របចង្កេះផ្អៀង។

❖ **អង្គុយបញ្ឈរជង្គង់ ពត់កដៃ**

ក. អង្គុយបញ្ឈរជង្គង់ ពត់កដៃឆ្វេង

- អង្គុយបញ្ឈរជង្គង់ឆ្វេង លាដៃឆ្វេងសន្ធឹង
- កែងដៃឆ្វេងដាក់លើក្បាលជង្គង់ឆ្វេង ដោយបង្វិលបាតដៃបញ្ឈរ
- លើកជើងស្តាំ (កជើង) គងលើ កដៃឆ្វេង
- កែងដៃស្តាំ ដាក់ស្របលើក្បាលជង្គង់ស្តាំ (ទម្លាក់ទម្ងន់ខ្លួនលើចង្កេះ ស្មាបើក ក្បាលងើបត្រង់ សម្លឹងទៅមុខ)
- ដៃស្តាំចាប់ពត់ប្រអប់ដៃឆ្វេង។

ខ. អង្គុយបញ្ឈរជង្គង់ ពត់កដៃស្តាំ

- អង្គុយបញ្ឈរជង្គង់ស្តាំ លាដៃស្តាំសន្ធឹង
- កែងដៃស្តាំ ដាក់លើក្បាលជង្គង់ស្តាំ ដោយបង្វិលបាតដៃបញ្ឈរ
- លើកជើងឆ្វេង (កជើង) គងលើ កដៃស្តាំ
- កែងដៃឆ្វេង ដាក់ស្របលើក្បាលជង្គង់ឆ្វេង (ទម្លាក់ទម្ងន់ខ្លួនលើចង្កេះ ស្មាបើក ក្បាលងើបត្រង់ សម្លឹងទៅមុខ)។
- ដៃឆ្វេងចាប់ពត់ប្រអប់ដៃស្តាំ។

វគ្គទី២៖

ក. អង្គុយបញ្ឈរជង្គង់ ជើងទាំងពីរបែកែងដៃចូលគ្នា

- អង្គុយបញ្ឈរជង្គង់ទាំងពីរ ប្រឹងម្រាមជើង
- ម្រាមដៃឆ្វេង និងម្រាមដៃស្តាំចាក់ស្រេះបញ្ចូលគ្នា ត្រឡប់បាតដៃទៅក្រៅ (ទៅមុខ)
- ដាក់កែងដៃទាំងពីរចូលក្នុងចន្លោះជង្គង់ទាំងពីរ
- ជើងទាំងពីរ របែកែងដៃឱ្យខិតជិតគ្នា (ទម្លាក់ទម្ងន់ខ្លួនលើចង្កេះ ប្រឹងដងខ្លួន ក្បាលងើបត្រង់ សម្លឹងទៅមុខ)។

ខ. អង្គុយរបៀបសត្វតោ

- ដៃទាំងពីរច្រត់ទៅមុខ
- ទម្លាក់ទម្ងន់ខ្លួន អង្គុយលើកែងជើងជំទើត
- យកកម្លាំងជង្គង់ទាំងពីរ រុញកែងដៃទាំងពីរ (ប្រឹងចង្កេះ ដងខ្លួនឱ្យទន់ ក្បាលងើបត្រង់សម្លឹងទៅមុខ)។

វគ្គទី៣៖ អង្គុយភ្នែនទ្រាល

ក. អង្គុយពែនភ្នែន

អង្គុយពែនភ្នែន ជើងទាំងពីរខ្ចាស់ចូលគ្នា ដៃទាំងពីរច្រត់ចង្កេះ ស្មាបើកទម្លាក់ចុះ ប្រឹងចង្កេះ

ខ. ទ្រាលផ្តាប់



- ទ្រាលផ្តាប់ទៅមុខ ពោះជាប់កម្រាល
- ដៃទាំងពីរបោះទៅមុខ ងើបមុខត្រង់។

គ. ទ្រាលផ្តាប់ : ងើបដងខ្លួន

- ពោះនៅជាប់នឹងកម្រាលដដែល
- ប្រឹងងើបដងខ្លួនត្រង់ ដៃទាំងពីរលាសន្ធឹង
- ដៃទាំងពីរច្រត់ទៅមុខត្រង់
- ក្បាលងើបត្រង់សម្លឹងទៅមុខ។

ឃ. ដេកផ្ងារ

- ក្រោកអង្គុយជើងខ្ចាស់ដដែល ដេកផ្ងារទៅក្រោយ
- ដៃទាំងពីរចាក់ស្រេះបញ្ចូលគ្នា ដាក់ទ្រាប់ក្បាល។

វគ្គទី៤៖ អង្គុយនិងឈរជៀវជើង

ក. អង្គុយជៀវជើងឆ្វេង

- អង្គុយលុតជង្គង់ឆ្វេង បង្ហើបជង្គង់ស្តាំ
- ដៃស្តាំជីប ដៃឆ្វេងលាបញ្ឈរ អង្គុយលើកែងជើងស្តាំជំទើត
- លុតជង្គង់ស្តាំ ទាញជើងឆ្វេងជៀវ
- កែងដៃឆ្វេង ដាក់លើបាតជើងឆ្វេង
- បាតដៃឆ្វេង លាសំយុងម្រាមដៃចុះ (ពត់ចង្កេះឆ្វេង)
- ដៃស្តាំវង់លា ត្រឹមកន្ទុយភ្នែក (ប្រមូលទម្ងន់ខ្លួន ដាក់លើជើងស្តាំ)។

ខ. អង្គុយជៀវជើងស្តាំ

- អង្គុយលុតជង្គង់ស្តាំ បង្ហើបជង្គង់ឆ្វេង
- ដៃឆ្វេងជីប ដៃស្តាំលាបញ្ឈរ អង្គុយលើកែងជើងឆ្វេងជំទើត
- លុតជង្គង់ឆ្វេង ទាញជើងស្តាំជៀវ
- កែងដៃស្តាំ ដាក់លើបាតជើងស្តាំ
- បាតដៃស្តាំលាសំយុងម្រាមដៃចុះ (ពត់ចង្កេះស្តាំ)
- ដៃឆ្វេងវង់លាត្រឹមកន្ទុយភ្នែក (ប្រមូលទម្ងន់ខ្លួន ដាក់មកលើជើងឆ្វេង)។

គ. ឈរជៀវជើងឆ្វេង

- ក្រោកឈរ លើជើងស្តាំ
- ដៃស្តាំជីប ដៃឆ្វេងលា
- ជើងឆ្វេង គោះទៅក្រោយ លើកឡើងជៀវ
- កែងដៃឆ្វេង ដាក់លើបាតជើងឆ្វេង
- បាតដៃឆ្វេង លាម្រាមដៃសំយុងចុះ (ពត់ចង្កេះឆ្វេង)
- ដៃស្តាំវង់លា ត្រឹមកន្ទុយភ្នែក (ប្រមូលទម្ងន់ខ្លួន ដាក់មកលើជើងស្តាំ)។

ឃ. ឈរជៀវជើងស្តាំ

- ទាញជើងឆ្វេង មកមុខជើងស្តាំ ទម្លាក់ចុះ
- ដៃឆ្វេងជីប ដៃស្តាំលា
- ជើងស្តាំគោះទៅក្រោយ លើកឡើងជៀវ
- កែងដៃស្តាំ ដាក់លើបាតជើងស្តាំ
- បាតដៃស្តាំ លាម្រាមដៃសំយុងចុះ (ពត់ចង្កេះស្តាំ)
- ដៃឆ្វេងវង់លាត្រឹមកន្ទុយភ្នែក (ប្រមូលទម្ងន់ខ្លួន ដាក់មកលើជើងឆ្វេង)

- អនុវត្តន៍

  សាកល្បងឱ្យសិស្សអនុវត្តម្នាក់ម្តង ឬមួយក្រុមម្តង។

មេរៀនទី២	**ចង្វាក់រាំវង់បែបទី១**
រយៈពេល	២ម៉ោង
វត្ថុបំណង	រាំចង្វាក់រាំវង់បែបទី១បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី៩៩ ដល់ទំព័រ១០០ រូបភាពទំព័រទី៨៣
ដំណើរការបង្រៀន	មើលលំនាំបង្រៀនដូនភ្ជាប់ខាងក្រោម
ចម្លើយសំណួរ	១. ៣ដំណាក់កាល ២. ត្រៀមលក្ខណៈ
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖**. ក **លំហាត់ទី២៖** ក

<u>ព័ត៌មានជំនួយ</u>៖

ដំណាក់	**ចលនាជើង**	**ចលនាដៃ**
- រៀបចំឥរិយាបថ	- ស្មាបើកទម្លាក់ ប្រឹងចង្កេះ ទម្លាក់ទម្ងន់ខ្លួនលើជើងឆ្វេង (រូបក្នុងស.ស.)។	- ដៃទាំងពីរលាបញ្ឈរដាក់ត្រឹមចង្កេះ។
ក. វគ្គទី១៖ - ដំណាក់ទី១ - ដំណាក់ទី២	- ឈានជើងស្តាំបញ្ជិតពីមុខជើងឆ្វេង - ឈានជើងឆ្វេងបញ្ជិតពីមុខជើងស្តាំបន្ត	- បង្វិលកដៃស្តាំជីបត្រឹមចង្កេះ - ដៃឆ្វេងរក្សាលំនឹងដដៃល - ដៃស្តាំជីបទាញឡើងយឺតៗ
- ដំណាក់ទី៣	- ថយជើងស្តាំមកក្រោយ បញ្ជិតទៅនឹងកែងជើងឆ្វេង	- ដៃឆ្វេងលាបញ្ឈរទាញឡើងយឺតៗ - ដៃស្តាំទាញឡើងលាត្រឹមកន្ទុយភ្នែកឬច្រមុះ។
ខ. វគ្គទី២៖	- អនុវត្តតាមលំនាំវគ្គទី១ គ្រាន់តែប្តូរដៃនិងជើងមកឆ្វេងប៉ុណ្ណោះ	- ដៃឆ្វេងលាបញ្ឈរទាញឡើងត្រឹមដើមទ្រូង។

ជំពូកទី១៣

ព្រះមហាក្សត្រនិងអ្នកដឹកនាំប្រទេស

រយៈពេល	៤ម៉ោង
វត្ថុបំណងមេរៀន	ប្រាប់ពីព្រះមហាក្សត្រនិងអ្នកដឹកនាំប្រទេសបានត្រឹមត្រូវ។
ចំណងជើងមេរៀន	
មេរៀនទី១	ព្រះមហាក្សត្រ
មេរៀនទី២	សាសនា
មេរៀនទី៣	ជាតិ
មេរៀនទី៤	ថ្នាក់ដឹកនាំប្រទេស

មេរៀនទី១	**ព្រះមហាក្សត្រ**
រយៈពេល	១ម៉ោង
វត្ថុបំណង	ប្រាប់ពីព្រះមហាក្សត្រខ្មែរបានត្រឹមត្រូវ។
សម្ភារៈឧបទេស	ស.ស. ទំព័រទី១០២ រូបភាពព្រះឆាយាល័ក្ខណ៍ព្រះមហាក្សត្រ
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រទី៦
ចម្លើយនៃសំណួរ	១. ស្ថិតនៅរាជធានីភ្នំពេញ ២. ព្រះនាម ព្រះបាទនរោត្តមសហមុនី
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ក. ១ព្រះអង្គ **លំហាត់ទី២៖** ខ. នរោត្តមសីហនុ

មេរៀនទី២	**សាសនា**
រយៈពេល	១ម៉ោង
វត្ថុបំណង	ប្រាប់ពីសាសនារបស់រដ្ឋបានត្រឹមត្រូវ។
សម្ភារៈឧបទេស	ស.ស. ទំព័រទី១០៣ ដល់ទំព័រ១០៤ រូបភាពទំព័រទី១០៣
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រទី៦
ចម្លើយនៃសំណួរ	១. សាសនាព្រះពុទ្ធ (ចម្លើយអាចមានផ្សេងទៀត) ២. ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ។

ចម្លើយ/កំណែលំហាត់	**លំហាត់៖** ក. ឱ្យប្រព្រឹត្តតែអំពើល្អ

មេរៀនទី៣	**ជាតិ**
រយៈពេល	១ម៉ោ
វត្ថុបំណង	ប្រាប់ពីចំនួនរាជធានី ខេត្ត និងចំនួនប្រជាជនបច្ចុប្បន្នបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី១០៤ ដល់ទំព័រ១០៤ រូបភាពរូបផែនទីប្រទេសកម្ពុជា
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រទី៦ សូមលោកគ្រូអ្នកគ្រូបង្រៀនតាមផែនទីប្រទេសកម្ពុជាដដែល ដោយគ្រាន់តែបញ្ជាក់ប្រាប់ឈ្មោះខេត្តដែលបង្កើតថ្មី គឺខេត្តត្បូងឃ្មុំ។
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ក. ២៤ខេត្ត **លំហាត់ទី២៖** ខ. ១៤លាននាក់

មេរៀនទី៤	**ថ្នាក់ដឹកនាំប្រទេស**
រយៈពេល	១ម៉ោង
វត្ថុបំណង	ប្រាប់ពីថ្នាក់ដឹកនាំប្រទេសបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី១០៥ ដល់ទំព័រទី១០៦ រូបភាពទំព័រទី១០៥
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រទី៦
ចម្លើយនៃសំណួរ	១. នៅប្រទេសកម្ពុជាមានព្រះមហាក្សត្រជាអ្នកគ្រងរាជ្យ។ ព្រះមហាក្សត្រទ្រង់គង់នៅក្នុងព្រះបរមរាជវាំង។ ២. នាយករដ្ឋមន្ត្រី ៣. ទីស្តីការគណៈរដ្ឋមន្ត្រី
ចម្លើយ/កំណែលំហាត់	**លំហាត់៖** ក. ស្តេច ខ. គោរព គ. អ្នកដឹកនាំ

ក្រសួងអប់រំ យុវជន និងកីឡា

និង

អង្គការដើម្បីភាពញញឹមនៃកុមារ





សូមថ្លែងអំណរគុណ

ចំពោះអ្នកខ្ចប់ត្តម្ភថវិកាដល់ដំណើរការគម្រោងចងក្រង និងបោះពុម្ពស្បៀវភៅពន្លឿនការសិក្សាដូចជា ៖
















រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

មាត្រា៦៥៖ *រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការអប់រំប្រកបដោយគុណភាពនៅគ្រប់កម្រិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាដំហានៗ ដើម្បីឱ្យការអប់រំនេះបានទៅដល់ប្រជាពលរដ្ឋគ្រប់រូប។ រដ្ឋយកចិត្តទុកដាក់លើវិស័យអប់រំកាយនិងកីឡាដែលជាសុខុមាលភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប។*

មាត្រា៦៦៖ *រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាពនៅទូទាំងប្រទេសដែលធានាឱ្យបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការ និងគោលការណ៍សមភាពក្នុងការអប់រំ ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូបមានភ័ព្វសំណាងគ្រប់គ្រាន់ស្មើគ្នាក្នុងការកសាងជីវិត។*

មាត្រា៦៧៖ *រដ្ឋអនុវត្តកម្មវិធីសិក្សានិងគោលការណ៍គរុកោសល្យទំនើបរាប់បញ្ចូលទាំងបច្ចេកវិទ្យានិងភាសាបរទេស។ រដ្ឋគ្រប់គ្រងគ្រឹះស្ថានសិក្សានិងថ្នាក់សិក្សាសាធារណៈនិងឯកជននៅគ្រប់ភូមិសិក្សា។*

មាត្រា៦៨៖ រដ្ឋផ្តល់កិច្ចការអប់រំផ្នែកបឋម និងមធ្យមសិក្សានៅសាលារៀនសាធារណៈសម្រាប់ប្រជាពលរដ្ឋគ្រប់រូបដោយឥតមានបង់ថ្លៃយ៉ាងតិច ៩ឆ្នាំ។

ច្បាប់ស្តីពីការអប់រំនៃព្រះរាជាណាចក្រកម្ពុជា

មាត្រា៣១៖ *ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិទទួលបានការអប់រំយ៉ាងតិច៩(ប្រាំបួន)ឆ្នាំប្រកបដោយគុណភាពដោយឥតបង់ថ្លៃនៅសាលារៀនសាធារណៈ។ ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវរៀបចំគោលនយោបាយផែនការយុទ្ធសាស្ត្រ និងវិធានការជាដំហានៗ ដើម្បីធានាឱ្យប្រជាពលរដ្ឋគ្រប់រូបទទួលបានការអប់រំប្រកបដោយគុណភាព ស្របតាមបទបញ្ញត្តិដែលមានចែងក្នុងច្បាប់នេះ។*

ការអប់រំសម្រាប់ទាំងអស់គ្នា!

ទាំងអស់គ្នាសម្រាប់ការអប់រំ!